ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ........✓.................

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណើរចូលរួមកិច្ចប្រជុំចង្អៀត រដ្ឋមន្ត្រីការពារជាតិអាស៊ាន របស់ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅទីក្រុងប៉េណាំង ប្រទេសម៉ាឡេស៊ី

តបតាមការអញ្ជើញរបស់**ឯកឧត្តម** Dato' Seri Mohamed Khaled bin Nordin រដ្ឋមន្ត្រីការពារជាតិម៉ាឡេស៊ី និងជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) និងកិច្ចប្រជុំពាក់ព័ន្ធឆ្នាំ២០២៥ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នឹងដឹកនាំប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ អញ្ជើញចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM Retreat) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥ នៅទីក្រុងប៉េណាំង ប្រទេសម៉ាឡេស៊ី។

កិច្ចប្រជុំចង្អៀត រដ្ឋមន្ត្រីការពារជាតិអាស៊ាន ឆ្នាំ២០២៥ ក្រោមមូលបទ **"ការឯកភាពអាស៊ាន ដើម្បីសន្តិសុខ និងវិបុលភាព"** នឹងផ្តោតលើកិច្ចពិភាក្សាផ្លាស់ប្តូរទស្សនៈស្តីពីការពង្រឹងឯកភាពអាស៊ាន និងជំរុញកិច្ចសហប្រតិបត្តិការតំបន់ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសន្តិសុខដែលកំពុងកើតមាន ព្រមទាំងគិតគូលើការពង្រឹងមជ្ឈភាពអាស៊ាន និងការធ្វើឱ្យកាន់តែមានប្រសិទ្ធិភាពនូវកិច្ចសហប្រតិបត្តិការជាក់ស្តែងក្រោមយន្តការ ADMM និង ADMM-Plus។

ជាមួយគ្នានោះ រដ្ឋមន្ត្រីការពារជាតិអាស៊ានក៏នឹងអនុម័ត **"សេចក្តីថ្លែងការណ៍រួម ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យបញ្ញាសិប្បនិម្មិតក្នុងវិស័យការពារជាតិ)** "Joint Statement by the ASEAN Defence Ministers on Cooperation in the Field of Artificial Intelligence in the Defence Sector( ។

ក្នុងឱកាសនៃកិច្ចប្រជុំចង្អៀតនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ** គ្រោងនឹងមានជំនួបពិភាក្សាទ្វេភាគីជាមួយសមភាគីអាស៊ានមួយចំនួន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការការពារជាតិដែលជាផលប្រយោជន៍រួមទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី។

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ.......✓.................

**Press Release**

**His Excellency General Tea Seiha, Deputy Prime Minister, Minister of National Defence**

**To Attend the ASEAN Defence Ministers' Meeting Retreat in Penang, Malaysia**

At the invitation of **His Excellency Dato' Seri Mohamed Khaled bin Nordin**, Minister of National Defence of Malaysia and Chairman of the ASEAN Defence Ministers' Meeting (ADMM) and related meetings in 2025, **His Excellency General Tea Seiha, Deputy Prime Minister, Minister of National Defence** will lead a high-level delegation of the Ministry of National Defence to attend the ASEAN Defence Ministers' Meeting Retreat (ADMM Retreat) from 25 to 27 February 2025 in Penang, Malaysia.

The theme of ASEAN Defence Ministers' Meeting Retreat 2025 is **"ASEAN Unity for Security and Prosperity."** The meeting will focus on exchange of views on strengthening ASEAN unity and promoting regional cooperation to address emerging security challenges as well as strengthening ASEAN centrality and enhancing the effectiveness of practical cooperation under the ADMM and ADMM-Plus mechanisms.

During this meeting, the ASEAN Defence Ministers will also adopt the **"Joint Statement by the ASEAN Defence Ministers on Cooperation in the Field of Artificial Intelligence in the Defence Sector."**

On the sideline of this ADMM Retreat, **His Excellency Deputy Prime Minister, Minister of National Defence** will hold bilateral discussions with several ASEAN counterparts to promote defence cooperation for common interest, both in bilateral and multilateral frameworks.

Phnom Penh, 21 February 2025